ការបកប្រែទិន្នន័យគម្រោង (PDS) នេះ គឺផ្អែកលើភាសាអង់គ្លេស ចុះនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥។

# ADB ធនាគារអភិវឌ្ឍន៍អាស៊ី

## កម្ពុជា ៖ កម្មវិធីអភិវឌ្ឍន៍វិស័យគ្រប់គ្រងសេវាសាធារណៈ និងហិរញ្ញវត្ថុបែបវិមជ្ឈការជំហានទី២

| | |
|---|---|
| **ឈ្មោះគម្រោង** | កម្មវិធីអភិវឌ្ឍន៍វិស័យគ្រប់គ្រងសេវាសាធារណៈ និងហិរញ្ញវត្ថុបែបវិមជ្ឈការជំហានទី២ |
| លេខគម្រោង | 49266-002 |
| ប្រទេស | កម្ពុជា |
| **ស្ថានភាពគម្រោង** | អនុម័ត |
| **ប្រភេទគម្រោង/គំរូនៃការផ្តល់ជំនួយ** | ជំនួយបច្ចេកទេស |
| ប្រភពមូលនិធិ/ចំនួន | TA 8929-CAM: **កម្មវិធីអភិវឌ្ឍន៍វិស័យគ្រប់គ្រងសេវាសាធារណៈ និងហិរញ្ញវត្ថុបែបវិមជ្ឈការជំហានទី២**<br>មូលនិធិពិសេសសម្រាប់ជំនួយបច្ចេកទេស — 800.000,00 ដុល្លារសហរដ្ឋអាមេរិក |
| **របៀបវារៈយុទ្ធសាស្រ្ត** | កំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នា |
| **កត្តាជម្រុញឱ្យមានការផ្លាស់ប្តូរ** | អភិបាលកិច្ច និង ការអភិវឌ្ឍន៍សមត្ថភាព<br>ដំណោះស្រាយផ្អែកចំណេះដឹង<br>ភាពជាដៃគូ |
| វិស័យ/អនុវិស័យ | ការគ្រប់គ្រងវិស័យសាធារណៈ - វិមជ្ឈការ |
| **សមធម៌យេនឌ័រ និងការបញ្ជ្រាបយេនឌ័រ** | ការបញ្ជ្រាបយេនឌ័រប្រកបដោយប្រសិទ្ធភាព |

**ការពណ៌នា**

ផលប៉ះពាល់របស់កម្មវិធីនេះ ដែលនឹងទទួលបានគឺជាការផ្តល់សេវាដែលកាន់តែមានប្រសិទ្ធភាព និងប្រកបដោយសមធម៌ប្រសើរជាងមុន តាមរយៈការធ្វើវិមជ្ឈការអំណាចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ លទ្ធផលដែលនឹងទទួលបានគឺសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ការផ្តល់សេវានឹងមានភាពប្រសើរជាងមុន។ លទ្ធផលនេះ នឹងអាចសម្រេចបានតាមរយៈការអនុវត្តន៍ធាតុចេញដូចខាងក្រោម ៖

ធាតុចេញទី១ ៖ សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ការផ្តល់សេវាបែបវិមជ្ឈការ ត្រូវបានពង្រឹង។ កំណែទម្រង់គោលនយោបាយដែលគេរំពឹងថានឹងទទួលបានក្រោមធាតុចេញនេះ រួមមាន ៖ (១) ការអនុវត្តន៍ពេញលេញនូវនិយ័តកម្ម ស្តីពីការធ្វើវិមជ្ឈការចំពោះការគ្រប់គ្រងធនធានមនុស្សទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (២) ការធ្វើប្រតិភូកម្មមុខងារពីក្រសួងសំខាន់ៗដូចជា ក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងបរិស្ថាន និង (៣) ការបង្កើតប្រព័ន្ធអភិវឌ្ឍន៍សមត្ថភាពសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ស្ថិតក្រោមធាតុចេញគោលនយោបាយនេះ ជំនួយបច្ចេកទេស (TA) នឹងត្រូវបានផ្តល់ជូនដើម្បីអភិវឌ្ឍន៍ (១) ក្របខ័ណ្ឌនិយ័តកម្មមួយ សម្រាប់ការអភិវឌ្ឍន៍សមត្ថភាពរបស់មន្ត្រីរាជការស៊ីវិលថ្នាក់ក្រោមជាតិ ដែលឆ្លុះបញ្ចាំងអំពីគោលនយោបាយស្តីពីយេនឌ័ររបស់រដ្ឋាភិបាល (២) សំណើកម្មវិធីសិក្សាដែលគិតគូចំពោះបញ្ហាយេនឌ័រសម្រាប់មន្ត្រីរាជការស៊ីវិលថ្នាក់ក្រោមជាតិ និង (៣) ការរៀបចំពេញលេញនិងការសិក្សាពិនិត្យលទ្ធភាពសម្រាប់ស្ថាប័នរដ្ឋាភិបាលមូលដ្ឋានមួយ។

ធាតុចេញទី២ ៖ ប្រភពចំណូលគ្រប់គ្រាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីបំពេញអាណត្តិការងាររបស់ពួកគេដែលត្រូវបានផ្តល់ឱ្យ។ កំណែទម្រង់គោលនយោបាយដែលគេរំពឹងថានឹងទទួលបានក្រោមធាតុចេញនេះ រួមមានការប្រគល់ប្រភពចំណូលពន្ធទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ វិចារណកម្មប្រព័ន្ធផ្ទេរ និង កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយនិរន្តរភាពនៅកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជំនួយបច្ចេកទេសសម្រាប់ការរៀបចំគម្រោង នឹងជួយអភិវឌ្ឍន៍ឱ្យមាននូវយុទ្ធសាស្ត្រអនុវត្តមួយសម្រាប់ការធ្វើវិមជ្ឈការពន្ធអចលនទ្រព្យទៅឱ្យស្រុក និង ក្រុង ដែលនេះគឺជាជម្រើសសមស្រប និង មានប្រសិទ្ធភាពខ្ពស់បំផុត ដើម្បីប្រគល់ប្រភព

| | |
|---|---|
| | ចំណូលផ្ទាល់ខ្លួនទៅឱ្យស្រុក និង ក្រុង។<br><br>ធាតុចេញទី៣ ៖ ប្រព័ន្ធគណនេយ្យភាពសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើត។ កំណែទម្រង់គោលនយោបាយស្ថិតក្រោមធាតុចេញនេះពាក់ពន្ធទៅនឹង (១) គោលការណ៍ណែនាំសម្រាប់អនុវត្តស្តីពីគណនេយ្យភាពរបស់អភិបាល ចំពោះក្រុមប្រឹក្សារបស់ពួកគេ (២) ការអនុវត្តន៍ក្របខ័ណ្ឌគណនេយ្យភាពសង្គម និង (៣) ការរៀបចំ និង ការអនុវត្តន៍ប្រព័ន្ធអធិការកិច្ចសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ សកម្មភាពជំនួយបច្ចេកទេសនឹងជួយដល់ការអនុវត្តន៍ក្របខ័ណ្ឌគណនេយ្យភាពសង្គម នៅក្នុងស្រុកមួយចំនួនដែលត្រូវបានជ្រើសរើស។ ក្នុងនោះរួមមាន ការអនុវត្តន៍គោលនយោបាយស្តីពីការបើកចំហសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំផែនការ និងថវិកា ដោយមានការចូលរួមពីប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងប្រព័ន្ធគណនេយ្យភាពរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋរបស់ពួកគេ។ |
| **សនិទានភាពគម្រោង និងការតភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រទេស/តំបន់** | ការទទួលបានសេវាសង្គមកម្រិតមូលដ្ឋានមិនស្មើភាពគ្នា ដោយសារតែកត្តាភូមិសាស្ត្រ គឺជាឧបសគ្គចម្បងមួយដែលរាំងស្ទះចំពោះកំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នានៅក្នុងប្រទេសកម្ពុជា។ ការផ្តល់សេវាប្រកបដោយគុណភាព នឹងពឹងផ្អែកកាន់តែច្រើនឡើងទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានជំនាញ និងមានគណនេយ្យភាព ដោយវាទាមទារឱ្យមានការវិនិយោគគួរឱ្យកត់សម្គាល់ទៅលើការអភិវឌ្ឍន៍សមត្ថភាព។ កម្មវិធីអភិវឌ្ឍន៍វិស័យគ្រប់គ្រងសេវាសាធារណៈ និង ហិរញ្ញវត្ថុបែបវិមជ្ឈការជំហានទី២ ដែលបានស្នើឡើង នឹងជួយកែលម្អសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការផ្តល់សេវាក្នុងមូលដ្ឋាន ដែលជាលក្ខខណ្ឌតម្រូវស្ថិតក្រោមផែនការអនុវត្តរយៈពេល៣ឆ្នាំ (២០១៥-២០១៨) របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)។<br><br>បើទោះបីជាភាពក្រីក្របានធ្លាក់ចុះគួរឱ្យកត់សម្គាល់នៅក្នុងប្រទេសកម្ពុជាក៏ដោយ ប៉ុន្តែភាពងាយរងគ្រោះនៅតែបន្តមានកម្រិតខ្ពស់ ហើយភាពខុសគ្នារវាងតំបន់ផ្សេងៗគ្នានៅតែបន្តមានទំហំធំគួរឱ្យកត់សម្គាល់។ អត្រាភាពក្រីក្រនៅកម្រិតថ្នាក់ជាតិ បានធ្លាក់ចុះពី ២២,៩% ក្នុងឆ្នាំ២០០៩ មក ១៨,៩% ក្នុងឆ្នាំ២០១២ ប៉ុន្តែខេត្តមួយចំនួនដែលស្ថិតនៅតាមដងទន្លេសាប |

និងភូមិភាគពាយព្យ នៅតែមានសេចក្តីរាយការណ៍ឱ្យដឹងថា អត្រាភាពក្រីក្រមានកម្រិតខ្ពស់ជាង ៣០%។ ប្រជាពលរដ្ឋរស់នៅតំបន់ជនបទត្រឹមតែ ៣៧% ប៉ុណ្ណោះ ដែលមានលទ្ធភាពទទួលបានអនាម័យប្រសើរជាងមុន និង ៤៤% មានលទ្ធភាពទទួលបានប្រភពទឹកស្អាត ដែលផ្ទុយពីប្រជាពលរដ្ឋនៅតំបន់ទីក្រុង ដែលលទ្ធភាពរបស់ពួកគេមានចំនួនច្រើនជាង ៧០%។ លទ្ធភាពទទួលបានសេវាសុខភាពនៅកម្រិតថ្នាក់ជាតិ ក៏មានភាពខុសគ្នាយ៉ាងទូលំទូលាយផងដែរនៅកម្រិតថ្នាក់ខេត្ត ហើយមានខេត្តជាច្រើនដែលនឹងមិនសម្រេចបានគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ សម្រាប់អត្រាមរណៈមាតា និងទារក។

បរិយាកាសច្បាប់មួយដ៏ទន់ខ្សោយ កង្វះមូលនិធិគ្រប់គ្រាន់សម្រាប់ការផ្តល់សេវា ការទទួលខុសត្រូវមិនច្បាស់លាស់សម្រាប់ការផ្តល់សេវា នៅក្នុងកម្រិតរដ្ឋបាលផ្សេងៗគ្នា និង យន្តការគណនេយ្យភាពទន់ខ្សោយ រវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋ អាចពន្យល់ឱ្យគេបានដឹងអំពីភាពខុសគ្នាដែលបានសង្កេតឃើញ ទាក់ទងទៅនឹងការគ្របដណ្តប់ និងគុណភាពនៃសេវាមូលដ្ឋាន។ រាជរដ្ឋាភិបាលបានចាប់ផ្តើមធ្វើប្រតិភូកម្មការទទួលខុសត្រូវចំពោះការផ្តល់សេវាស្នូល ទៅឱ្យស្រុក និងក្រុង។ ការធ្វើវិមជ្ឈការនេះនឹងបង្កឱ្យមាននូវបញ្ហាប្រឈម សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងនេះ អាស្រ័យដោយពួកគេធ្វើប្រតិបត្តិការនៅក្នុងប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន ដែលពុំមានបទពិសោធន៍ និង ស្ថិតក្រោមទេយ្យទានធនធានដ៏ទន់ខ្សោយ។ ចំណាយសរុបដោយរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងប្រទេសកម្ពុជា មានចំនួន ៧% នៃចំណាយសាធារណៈជារួម ក្នុងឆ្នាំ២០១៤ ដែលក្នុងនោះ ស្រុក និងក្រុង (ដែលជាការផ្តោតយកចិត្តទុកដាក់នៃកិច្ចខិតខំវិមជ្ឈការ) មានចំណែកប្រើប្រាស់ចំនួន ២០%។

ការវិនិយោគទ្រង់ទ្រាយធំ ត្រូវការបង្កើនជំនាញរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ វឌ្ឍនភាពស្តីពីវិមជ្ឈការចំណាយ និងចំណូល ត្រូវរួមផ្សំជាមួយការវិនិយោគគួរឱ្យកត់សម្គាល់មួយចំនួន ទៅលើការអភិវឌ្ឍន៍សមត្ថភាពរបស់សេវាសាធារណៈក្នុងមូលដ្ឋាន ដើម្បីអនុញ្ញាតឱ្យមានការផ្តល់សេវាប្រកបដោយប្រសិទ្ធភាពខ្ពស់ និង ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ។ មានបុគ្គលិកជាង ១០.០០០នាក់ ដែលបម្រើការងារនៅក្នុងរដ្ឋបាលស្រុក និង ក្រុងក្នុងប្រទេសកម្ពុជា ទាមទារឱ្យមានការអភិវឌ្ឍន៍

| | |
|---|---|
| | ជំនាញក្នុងវិស័យជាច្រើន។ ចំណុចនេះអំពាវនាវឱ្យមានការសម្របសម្រួលអន្តរទីភ្នាក់ងារ និងការផ្តល់មូលនិធិគាំទ្រឱ្យបានគ្រប់គ្រាន់។<br><br>ចាប់តាំងពីឆ្នាំ២០១៣ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានប្រគល់ប្រភពចំណូលមិនមែនពន្ធ (ថ្លៃសេវា និងកម្រៃនានា) រួមទាំងការផ្ទេរសារពើពន្ធ។ បើទោះបីជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់បែបនេះក៏ដោយ ប៉ុន្តែនៅមានការងារសេសសល់ជាច្រើនទៀតដែលត្រូវធ្វើ ដើម្បីកសាងមូលដ្ឋានចំណូលដ៏រឹងមាំ និងមានភាពទូលំទូលាយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ សកម្មភាពនេះរួមមាន (១) ការប្រគល់ចំណូលពន្ធទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលជាធាតុមួយដ៏សំខាន់នៃគណនេយ្យភាព រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និង ប្រជាពលរដ្ឋក្នុងមូលដ្ឋាន (២) ការធានាឱ្យមានការបែងចែកប្រកបដោយសមធម៌ ចំពោះការផ្ទេរសារពើពន្ធ និង (៣) ការអនុវត្តន៍យកថ្លៃសេវា និង ការកំណត់យកកម្រៃពីអ្នកប្រើប្រាស់ ប្រកបដោយប្រសិទ្ធភាពខ្ពស់សម្រាប់ការផ្តល់សេវាសាធារណៈក្នុងមូលដ្ឋាន។ |

ផលប៉ះពាល់

## លទ្ធផលគម្រោង

ការពណ៌នាអំពីលទ្ធផល

វឌ្ឍនភាពធៀបនឹងលទ្ធផល

## វឌ្ឍនភាពនៃការអនុវត្តន៍

ការពណ៌នាអំពីទិន្នផលគម្រោង

ស្ថានភាពនៃវឌ្ឍនភាពចំពោះការអនុវត្តន៍ (ទិន្នផល សកម្មភាព និង បញ្ហា)

ទីតាំងភូមិសាស្រ្ត

## សង្ខេបអំពីបញ្ហាបរិស្ថាន និងបញ្ហាសង្គម

បញ្ហាបរិស្ថាន

ការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត

ជនជាតិដើមភាគតិច

## ការប្រាស្រ័យទាក់ទង ការចូលរួម និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

ក្នុងអំឡុងពេលនៃការរៀបចំគម្រោង

ក្នុងអំឡុងពេលនៃការអនុវត្តន៍គម្រោង

## កាលានុវត្តភាពធុរកិច្ច

សេវាទីប្រឹក្សា ៖ ទីប្រឹក្សាមកពីក្រុមហ៊ុន ព្រមទាំងទីប្រឹក្សាជាបុគ្គល នឹងត្រូវបានទាក់ទងឱ្យបម្រើការងារ ក្នុងនោះរួមមានទីប្រឹក្សាអន្តរជាតិចំនួន ២៥នាក់ក្នុងមួយខែ និង ទីប្រឹក្សាជាតិ ចំនួន ៥០នាក់ក្នុងមួយខែ។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងជ្រើស ព្រមទាំងទាក់ទងផ្តល់ការងារជូនទីប្រឹក្សាតាមរយៈគោលការណ៍ណែនាំរបស់ខ្លួន ស្តីពីការប្រើប្រាស់ទីប្រឹក្សា (ឆ្នាំ២០១៣ ហើយបានធ្វើវិសោធនកម្មជាបន្តបន្ទាប់)។ ក្រុមហ៊ុនផ្តល់សេវាទីប្រឹក្សានឹងត្រូវបានជ្រើសរើស ដោយប្រើប្រាស់វិធីសាស្ត្រជ្រើសរើសផ្អែកលើថវិកាកំណត់។ មូលនិធិយថាភាពមួយចំនួន នឹងនៅតែបន្តមិនត្រូវបានវិភាជន៍សម្រាប់ទីប្រឹក្សាជាបុគ្គល ដែលត្រូវបានកំណត់ទៅតាមភាពចាំបាច់។ នៅពេលបញ្ចប់ជំនួយបច្ចេកទេស ឧបករណ៍សម្ភារៈដែលត្រូវបានធ្វើលទ្ធកម្មក្រោមជំនួយបច្ចេកទេសនេះ នឹងត្រូវផ្ទេរទៅឱ្យទីភ្នាក់ងារប្រតិបត្តិ។

| | |
|---|---|
| មន្ត្រីធនាគារអភិវឌ្ឍន៍អាស៊ី ដែលទទួលខុសត្រូវ | Juan Gomez Reino |
| នាយកដ្ឋានធនាគារអភិវឌ្ឍន៍អាស៊ី ដែលទទួលខុសត្រូវ | នាយកដ្ឋានអាស៊ីអាគ្នេយ៍ |
| ផ្នែករបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលទទួលខុសត្រូវ | ផ្នែកគ្រប់គ្រងសាធារណៈ វិស័យហិរញ្ញវត្ថុ និង ពាណិជ្ជកម្ម នៃ SERD |
| ទីភ្នាក់ងារប្រតិបត្តិ | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ<br>ក្រសួងមហាផ្ទៃ<br>មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ |

| កាលវិភាគ | |
|---|---|
| **ការអនុម័តលើទស្សនទាន** | - |
| **បេសកកម្មស្វែងរកការពិត** | - |
| **កិច្ចប្រជុំត្រួតពិនិត្យឡើងវិញរបស់ថ្នាក់គ្រប់គ្រង** | - |
| **ការអនុម័ត** | ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥ |
| បេសកកម្មត្រួតពិនិត្យលើកចុងក្រោយ | - |
| បច្ចុប្បន្នភាពទិន្នន័យគម្រោងចុងក្រោយ | ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ |

TA 8929-CAM: **កម្មវិធីអភិវឌ្ឍន៍វិស័យគ្រប់គ្រងសេវាសាធារណៈ និង ហិរញ្ញវត្ថុបែបវិមជ្ឈការជំហានទី២**

| ព្រឹត្តិការណ៍សំខាន់ៗ | | | | | |
|---|---|---|---|---|---|
| ការអនុម័ត | ការចុះហត្ថលេខា | ការចូលជាធរមាន | ការបិទ | | |
| | | | កំណត់ពីដំបូង | កែសម្រួលឡើងវិញ | ជាក់ស្តែង |
| ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥ | - | - | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | - | - |

| ផែនការផ្តល់ហិរញ្ញប្បទាន/ការប្រើប្រាស់ជំនួយបច្ចេកទេស | | | | | | | ការដកសាច់ប្រាក់សរុប | |
|---|---|---|---|---|---|---|---|---|
| ធនាគារអភិវឌ្ឍន៍អាស៊ី | សហហិរញ្ញប្បទាន | សមភាគី | | | | សរុប | កាលបរិច្ឆេទ | ចំនួន |
| | | រដ្ឋាភិបាល | អ្នកទទួលផល | អ្នកឧបត្ថម្ភគម្រោង | ផ្សេងៗ | | | |
| ៨00.000,00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | ៨00.000,00 | ០៣ កក្កដា ២០១៥ | 0.00 |

ទិន្នន័យគម្រោង (PDS) រួមមានព័ត៌មានសង្ខេបអំពីគម្រោង ឬ កម្មវិធី ៖ អាស្រ័យដោយ PDS គឺជាការងារមួយដែលកំពុងបន្ត ដូច្នេះព័ត៌មានមួយចំនួនអាចមិនត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងបឋម ប៉ុន្តែ ព័ត៌មានទាំងនោះនឹងត្រូវយកមកបន្ថែមនៅពេលដែលមានព័ត៌មាន។ ព័ត៌មានអំពីសំណើគម្រោង គឺជាព័ត៌មានដែលអាចមានការប្រែប្រួល និង ជាព័ត៌មានបណ្តោះអាសន្នតែប៉ុណ្ណោះ។

ធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់ព័ត៌មាននៅក្នុងទិន្នន័យគម្រោងនេះ (PDS) ដើម្បីជាធនធានសម្រាប់អ្នកប្រើប្រាស់តែប៉ុណ្ណោះ ដោយពុំមានការធានាក្នុងទម្រង់ណាមួយឡើយ។ បើទោះបីជាធនាគារអភិវឌ្ឍន៍អាស៊ីព្យាយាមផ្តល់មាតិកាប្រកបដោយគុណភាពខ្ពស់ក៏ដោយ ប៉ុន្តែព័ត៌មានត្រូវបានផ្តល់ជូន "ក្នុងលក្ខណៈមួយ" ដែលពុំមានការធានាក្នុងទម្រង់ណាមួយទេ មិនចំពោះថាជាការធានាដែលមានការបញ្ជាក់ច្បាស់លាស់ ឬ ជាការបង្កប់អត្ថន័យឡើយ រាប់បញ្ចូលការពុំមានកំណត់ទៅលើការធានាចំពោះភាពសមស្របសម្រាប់ទីផ្សារ ភាពសមស្របសម្រាប់គោលបំណងជាក់លាក់មួយ និង ការមិនរំលោភបំពាន។ ជាពិសេស ធនាគារអភិវឌ្ឍន៍អាស៊ីមិនផ្តល់ការធានាណាមួយទៅលើសុក្រឹត្យភាព ឬ ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មាននេះឡើយ។